## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
## និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# កិច្ចការស្រាវជ្រាវ

# ទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិ
# ប្រទេសសង្ហិបុរី ចិន អាមេរិក និង កម្ពុជា


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **នុត វណ្ណៈ**

សាស្ត្រាចារ្យណែនាំ

លោក **ចាយចន្ទ តារាវណ្ណ**


ថ្នាក់**បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ**

ជំនាញ**នីតិឯកជន** ជំនាន់ទី១០

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរកិច្ចការស្រាវជ្រាវ ២០១៣


**រក្សាសិទ្ធិដោយ Khmer Famous**

# នីតិសាជីវកម្មប្រៀបធៀប

## ១.ទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិប្រទេសសង្ហបុរី ចិន អាមេរិក និង កម្ពុជា

### I. ទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិប្រទេសសង្ហបុរី បែងចែកជាបី៖

#### 1. សហកម្មសិទ្ធទូទៅ (General Partner Ship)

-ជាអង្គភាពជំនួញមានការចូលរួមបង្កើតពីមនុស្សពីរនាក់ ឬច្រើននាក់

-គ្មាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីម្ចាស់

-ជាអង្គភាពជំនួញមិនសូវមានប្រជាប្រិយទេ

-សហកម្មសិទ្ធិករទទួលខុសត្រូវផ្ទាល់ចំពោះបំណុល និងការទទួលខុសត្រូវរបស់អង្គភាពជំនួញ

-សមាជិកម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះសកម្មភាពរបស់សហកម្មសិទ្ធិករដទៃទៀត

-សមាជិកអតិបរមាមិនលើសពី ២០នាក់

-អាចហៅវាថា (Firm)

-សមាជិក ជាម្ចាស់លើទ្រព្យសហកម្មសិទ្ធិរួមគ្នា

-ទទួលខុសត្រូវគ្មានកំរិត (Unlimited Liability)

#### 2. សហកម្មសិទ្ធមានកំរិត (Limited Partner Ship)

-ជាទម្រង់ក្រុមហ៊ុនមួយ មិនសូវទាក់ទាញ

-មានសមាជិកពីរប្រភេទ៖ គឺ Limited Partner និង General Partner

-សមាជិក Limited Partner ទទួលខុសត្រូវត្រឹមដើមទុនដែលខ្លួនបានវិនិយោគក្នុងសហកម្មសិទ្ធិ Limited Partner គ្មានសិទ្ធិចូលរួមក្នុងការដឹកនាំគ្រប់គ្រងអាជីវកម្មទេ។

#### 3. Limited Liability Partner Ship (LLP)

-ជាទម្រង់មួយដ៏ពេញនិយមមួយ ដែលទើបតែបង្កើតនៅឆ្នាំ២០០៥ វាជាទម្រង់មួយដែលបញ្ចូលគ្នានូវលក្ខណៈសហកម្មសិទ្ធ និង ក្រុមហ៊ុន (Private Limited Company)

-ម្ចាស់មានសិទ្ធិដឹកនាំអាជីវកម្មដូចសហកម្មសិទ្ធិ ប៉ុន្តែអនុញ្ញាតឱ្យសមាជិកមិនទទួលខុសត្រូវ

ផ្ទាល់ខ្លួនចំពោះសកម្មភាពរបស់សហកម្មសិទ្ធិផ្សេងទៀត

-ការពារទទួលខុសត្រូវជាទូទៅត្រឹមកំរិតនៃការទទួលខុសត្រូវដែលកើតចេញពីការប្រព្រឹត្តមិនត្រឹមត្រូវដែលធ្វើដោយសមាជិកដទៃទៀត។ សមាជិកមិនទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះការប្រព្រឹត្តខុសរបស់សមាជិកដទៃទៀត។

-សមាជិកមិនទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះបំណុលនៃ LLP នេះទេ

-LLP គឺជាម្ចាស់នៃទ្រព្យក្នុងនាមខ្លួន

-មានសមាជិក General Partner Ship យ៉ាងតិចម្នាក់ និង Limited Partner យ៉ាងតិចម្នាក់

-LLP ទទួលត្រូវខុសត្រូវចំពោះប្រាក់ចំណេញ និង ការខាតបង់សំរាប់អង្គភាពជំនួញ

-មានលក្ខណៈជានីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីសហកម្មសិទ្ធិករ។

## II. ទម្រង់សហគ្រាសសហកម្មសិទ្ធិប្រទេសចិន បែងចែកជាបី៖

### 1. សហគ្រាសសហកម្មសិទ្ធិទូទៅ

-បង្កើតឡើងដោយសហកម្មសិទ្ធិករទូទៅ

-សហកម្មសិទ្ធិករទទួលខុសត្រូវគ្មានកម្រិតរួមគ្នាចំពោះបំណុលសហគ្រាសសហកម្មសិទ្ធិ

-មានសហកម្មសិទ្ធិករ ពីរ ឬច្រើននាក់

-មានកិច្ចព្រមព្រៀងសហកម្មសិទ្ធិ

-មានការបង់ដើមទុនដោយសហកម្មសិទ្ធិករ

-មានឈ្មោះ និងទីស្នាក់ការប្រតិបត្តិការអាជីវកម្មផលិតកម្ម

-សហកម្មសិទ្ធិករអាចចូលជាប្រាក់ វត្ថុ សិទ្ធិកម្មសិទ្ធិបញ្ញា សិទ្ធិប្រើប្រាស់ដី ទ្រព្យ ឬកំលាំងពលកម្ម

-ទ្រព្យដែលសហកម្មសិទ្ធិករ បង់ជាទ្រព្យរបស់សហគ្រាសសហកម្មសិទ្ធិ

-ពេលជម្រះបញ្ជី គ្មានសហកម្មសិទ្ធិករណាម្នាក់អាចស្នើសុំបែងចែកទ្រព្យរបស់សហគ្រាសសហកម្មសិទ្ធិទេ

-សហកម្មសិទ្ធិករទាំងអស់មានសិទ្ធិសម្រេចស្មើគ្នាក្នុងការអនុវត្តកិច្ចការរបស់សហកម្មសិទ្ធិ

-សហកម្មសិទ្ធិករណាដែលមិនបានអនុវត្តកិច្ចការអាជីវកម្ម របស់សហកម្មសិទ្ធិមានសិទ្ធិ ត្រួតពិនិត្យការអនុវត្តនេះ។ជាកិច្ចការដែលត្រូវសម្រេចជាឯកច្ឆ័នពីសហកម្មសិទ្ធិករទាំងអស់រួមមាន៖

- ការផ្លាស់ប្តូរសហកម្មសិទ្ធិ
- ការផ្លាស់ប្តូរវិសាលភាពនៃអាជីវកម្ម
- ការចាត់ចែងអចលនទ្រព្យរបស់សហកម្មសិទ្ធិ
- ការចាត់ចែងសិទ្ធិលើកម្មសិទ្ធិបញ្ញា
- ការដាក់ធានាបំណុលក្នុងនាមក្រុមហ៊ុន
- ជួលអ្នកចាត់ចែង
- ការបន្ថយ ឬបង្កើនដើមទុន

-សហកម្មសិទ្ធិករមិនអាចប្រកបអាជីវកម្មណាដែលប្រកួតប្រជែងជាមួយសហគ្រាសសហកម្មសិទ្ធិករទេ

-សហកម្មសិទ្ធិករមិនអាចធ្វើសកម្មភាពណាដែលនាំឱ្យខូចដល់ប្រយោជន៍សហគ្រាសសហកម្មសិទ្ធិ

-ការបែងចែកប្រាក់ចំណេញ និងការខាតបង់ត្រូវធ្វើឡើងតាមសមាមាត្រនៃដើមទុនដែលបានបង់ លើកលែងតែ មានចែងដោយឡែកក្នុងកិច្ចព្រមព្រៀង

-ការចូលជាសហកម្មសិទ្ធិករថ្មី ត្រូវមានការយល់ព្រមពីសហកម្មសិទ្ធិករទាំងអស់ជាឯកច្ឆ័ន លើកលែងតែ មានក្នុងកិច្ចព្រមព្រៀងដោយឡែក។ សមាជិកថ្មីត្រូវទទួលខុសត្រូវរួមគ្នាចំពោះបំណុលរបស់សហកម្មសិទ្ធិដែលមានមុនពេលត្រូវបានទទួលឱ្យចូលជាសមាជិកថ្មី។

-សមាជិកដែលចង់ដកខ្លួនចេញ ត្រូវជូនដំណឹង ៣០ថ្ងៃមុន។ ការដកខ្លួនចេញអាចធ្វើបានតែក្នុងករណីដូចខាងក្រោះ

- មានមូលហេតុដូចកិច្ចព្រមព្រៀង
- សមាជិកទាំងអស់យល់ព្រមឱ្យដកខ្លួនចេញ
- មូលហេតុផ្សេងៗដែលធ្វើឱ្យសមាជិកមិនអាចនៅក្នុងសហកម្មសិទ្ធិទៀតបាន។

-សមាជិកដទៃទៀត រំលោភលកាតព្វកិច្ចខ្លួនដូចមានចែងក្នុងកិច្ចព្រមព្រៀងធ្ងន់ធ្ងរពេក
-សមាជិកអាចត្រូវបានចាត់ទុកថា ដកខ្លួនចេញពីសហកម្មសិទ្ធិបើៈ

- ស្លាប់
- ក្ស័យធន
- ចំពោះនីតិបុគ្គលជាសមាជិកត្រូវបានដកអាជ្ញាប័ណ្ណ ឬបិទ ឬត្រូវប្រកាសថាក្ស័យធន
- បាត់សមាជិក ដោយបាត់លក្ខណៈសម្បត្តិតំរូវតាមច្បាប់
- ចំណែកហ៊ុនរបស់សហកម្មសិទ្ធិករក្នុងសហកម្មសិទ្ធិករត្រូវបានរឹបអូសដោយតុលាការ

-សមាជិកត្រូវបានបណ្តេញចេញ កាលណាៈ

- មិនបង់ប្រាក់ដើមទុក
- បង្កឱ្យមានការខាតបង់ធ្ងន់ធ្ងរដោយកំហុសចេតនា ឬអចេតនា ធ្ងន់ធ្ងររបស់ខ្លួន
- ធ្វើសកម្មភាពមិនត្រឹមត្រូវ
- មានមូលហេតុដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង

-បើសមាជិកស្លាប់ ទាយាទអាចក្លាយជាសមាជិកជំនួសក្នុងសហកម្មសិទ្ធិតែត្រូវមានការយល់ព្រមជា  ឯកច្ឆ័នពីសមាជិក។

## 2. សហគ្រាសសហកម្មសិទ្ធិទទួលខុសត្រូវមានកម្រិត

-បង្កើតដោយសហកម្មសិទ្ធិករទូទៅ និងសហកម្មសិទ្ធិករមានកម្រិត
-សមាជិកជាសហកម្មសិទ្ធិករទូទៅ ទទួលខុសត្រូវគ្មានកម្រិតនិងរួមគ្នាចំពោះបំណុលនៃសហគ្រាសសហកម្មសិទ្ធិ។
-សមាជិកជាសហកម្មសិទ្ធិករមានកម្រិតទទួលខុសត្រូវចំពោះបំណុលត្រឹមដើមទុនដែលខ្លួនបានចូលរួម
-គ្មានក្រុមហ៊ុនរដ្ឋ ក្រុមហ៊ុនក្នុង Stock Exchange ឬគ្រឹះស្ថានសាធារណៈ ឬអង្គការសង្គមអាច

ក្លាយជាសហកម្មសិទ្ធិករទូទៅទេ

-មានកិច្ចព្រមព្រៀងសហកម្មសិទ្ធិ កិច្ចព្រមព្រៀងត្រូវកំណត់ពីល័ក្ខខ័ណ្ឌ តើសហកម្មសិទ្ធិករណាដែលមានសិទ្ធិចាត់ចែងកិច្ចការសហកម្មសិទ្ធិ។ កំណត់ពីព្រំដែននៃសិទ្ធិ និងនីតិវិធីសម្រាប់ជ្រើសរើសសមាជិកនោះ

-មានសមាជិកមិនតិចជាងពីរនាក់ និងមិនលើសពី ៥០នាក់ លើកលែងតែច្បាប់ចែងដោយឡែក

-ត្រូវមានសមាជិកជាសហកម្មសិទ្ធិទូទៅយ៉ាងតិច ១នាក់

-សហកម្មសិទ្ធិមានកម្រិតអាចបង់ដើមទុនជាសាច់ប្រាក់ វត្ថុ សិទ្ធិបញ្ញា សិទ្ធិប្រើប្រាស់ ឬ ទ្រព្យ តែមិនអាចចូលជាកំលាំងពលកម្មបានទេ

-កិច្ចការអាជីវកម្មរបស់សហកម្មសិទ្ធិត្រូវធ្វើដោយសហកម្មសិទ្ធិករទូទៅ ហើយអាចទទួលបានប្រាក់កំរៃបាន

-សហកម្មសិទ្ធិមានកម្រិតមិនអាចចាត់ចែងអាជីវកម្មបានទេ និង មិនអាចធ្វើជាតំណាងសហកម្មសិទ្ធិករទេ

-តែសហកម្មសិទ្ធិករមានកម្រិតអាចៈ

- ចូលរួមសម្រេចចិត្តលើការទទួល ឬ ដកខ្លួនសមាជិកទូទៅ
- ស្នើពីរបៀបគ្រប់គ្រងសហគ្រាស
- ចូលរួមជ្រើសរើសក្រុមហ៊ុនគណនេយ្យ
- ទទួលបានរបាយការណ៍ហិរញ្ញវត្ថុ
- អាចប្តឹងសមាជិកដែលត្រូវទទួលខុសត្រូវ បើទង្វើនោះមានការខូចខាតដល់ប្រយោជន៍សហកម្មសិទ្ធិ

## 3. សហគ្រាសសហកម្មសិទ្ធិទូទៅពិសេស

-ស្ថាប័នផ្តល់សេវាវិជ្ជាជីវៈដល់អតិថិជនដោយប្រើប្រាស់ចំណេះ និងជំនាញអាចបង្កើត សហគ្រាសពិសេស

-គឺជាសហគ្រាសសហកម្មសិទ្ធិទូទៅដែលសមាជិកម្នាក់ ឬច្រើននាក់ទទួលខុសត្រូវគ្មានកម្រិត

ចំពោះបំណុលដែលសហគ្រាសទទួលរងដោយសារតែ អំពើចេតនា ឬកំហុសធ្ងន់ធ្ងររបស់ខ្លួនឬរបស់ពួកគេ។ សហកម្មសិទ្ធិករទាំងអស់ទទួលខុសត្រូវរួមគ្នាចំពោះបំណុល ដែលបង្កឡើងដោយសហកម្មសិទ្ធិករណាម្នាក់ចំពោះសហគ្រាសសហកម្មសិទ្ធិ

-សមាជិកដែលប្រព្រឹត្តខុសនោះត្រូវទទួលខុសត្រូវសងការខាតបង់នោះដល់សហកម្មសិទ្ធិបើសហកម្មសិទ្ធិបានទទួលរងបំណុលដោយសារតែ ការប្រព្រឹត្តរបស់សមាជិកនោះ

-សហគ្រាសសហកម្មសិទ្ធិពិសេសនេះ ត្រូវបំរុងមូលនិធិទិញធានារ៉ាប់រងលើ Mal Practic។ ប្រាក់ធានារ៉ាប់រងនេះ ទុកទូទាត់បំណុលនោះ។

## III. ទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិសហរដ្ឋអាមេរិកះ

-ក្រុមហ៊ុនសហកម្មសិទ្ធិ គឺមិនជាក្រុមហ៊ុនពីរ បញ្ចូលគ្នាទេ

-ក្រុមហ៊ុនសហកម្មសិទ្ធិ គឺជាការសហការគ្នា រវាងបុគ្គលម្នាក់ជាមួយនឹងបុគ្គលម្នាក់ ឬច្រើននាក់ដើម្បីបង្កើតជាក្រុមហ៊ុនមួយ

-ក្រុមហ៊ុនសហកម្មសិទ្ធិ ត្រូវបានបែងចែក ជាអង្គភាពជាច្រើន ដោយម្ចាស់ភាគហ៊ុនច្រើននាក់ ដែលខុសគ្នាពីការសហការ

-សហកម្មសិទ្ធិត្រូវតែមាន យ៉ាងតិចណាស់ សមាជិកសហកម្មសិទ្ធិទូទៅម្នាក់ ដែលទទួលខុសត្រូវដោយគ្មានកម្រិតសំរាប់ការធ្វើអាជីវកម្មរបស់ខ្លួន

-សហកម្មសិទ្ធិ ត្រូវតែមាន ម្ចាស់ភាគហ៊ុន យ៉ាងតិចណាស់ពីរនាក់

-សហកម្មសិទ្ធិ ត្រូវចូលរួមចំណែកទទួលខុសត្រូវ ចំពោះប្រាក់ចំណេញ និង ខាតរបស់ខ្លួនទាំងអស់

### 1. ម្ចាស់ក្រុមហ៊ុនមួយ និង ប្រតិបត្តិដោយ បុគ្គលច្រើនជាង ១នាក់

-ម្ចាស់ក្រុមហ៊ុន ត្រូវទទួលខុសត្រូវមានកម្រិត សំរាប់ការធ្វើអាជីវកម្មក្នុងក្រុមហ៊ុនរបស់ខ្លួន

-អាចពង្រីកអាជីវកម្មរបស់ខ្លួន តាមរយៈការលក់ភាគហ៊ុន និង មូលបត្រ

-ក្រុមហ៊ុនអាចជួលអ្នកជំនាញគ្រប់គ្រង និង ផ្លាស់ប្តូរបុគ្គិល នៅពេលមានការចាំបាច់

-Firm has potentially and legal eternal life-owners may come and go or die

2. **គុណសម្បត្តិ**

-ជាទម្រង់ក្រុមហ៊ុន ងាយស្រួលបង្កើត
-ចូលដើមទុនច្រើនជាងម្ចាស់
-ជាក្រុមហ៊ុនឯកទេសពិតប្រាកដ មានការគ្រប់គ្រងច្បាស់លាស់
-ប្រាក់ចំណូល គឺជាការបង់ពន្ធតែម្តង

3. **គុណវិបត្តិ**

-មិនមានការយល់ព្រម ក្នុងចំណោមសហកម្មសិទ្ធិ ក្នុងការសម្រេចដើម្បីដោះស្រាយបញ្ហា
-ទទួលខុសត្រូវគ្មានកម្រិត ចំពោះសហកម្មសិទ្ធិ
-មាននីតវិធីច្បាប់ស្មុកស្មាញ នៅពេលសហកម្មសិទ្ធិស្លាប់ ឬ ចាក់ចេញ។

IV. **ទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិប្រទេសកម្ពុជាបែងចែកជាពីរៈ**

**1.ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ**

-មានសមាជិកតែ មួយប្រភេទ គឺសហកម្មសិទ្ធិករទូទៅ
-ក្រុមហ៊ុនបង្កើតឡើងដោយកិច្ចសន្យារវាងបុគ្គលពីរនាក់ ឬច្រើននាក់ ធ្វើឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ
-សមាជិកទាំងអស់ មានសិទ្ធិដឹកនាំអាជីវកម្មស្មើគ្នា ដោយឯកឆ្ឆ័ន
-សមាជិកទាំងអស់ទទួលខុសត្រូវរួមគ្នា និងដោយឡែកពីគ្នា ចំពោះកាតព្វកិច្ចទាំងឡាយរបស់ក្រុមហ៊ុន
-សមាជិកទាំងអស់ អាចចូលជាចំណេះបាន
-ចែកប្រាក់ចំណេញ និងខាត់ស្មើគ្នា (លើកលែងតែ មានចែងក្នុងកិច្ចព្រមព្រៀងដោយឡែក)
-គ្មានសមាជិកណា ម្នាក់ទទួលបានប្រាក់បៀវត្តន៍ពីក្រុមហ៊ុនទេ។

## 2.ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត

-មានសមាជិក ពីរប្រភេទ៖

- ○ សហកម្មសិទ្ធិករទូទៅ
- ○ សហកម្មសិទ្ធិករមានកម្រិត

-ក្រុមហ៊ុនបង្កើតឡើងដោយកិច្ចសន្យារវាងបុគ្គលពីរនាក់ ឬច្រើននាក់ ធ្វើឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ

-សមាជិកមានឋានៈទូទៅ មានសិទ្ធិសម្រេច និង ដឹកនាំអាជីវកម្មក្រុមហ៊ុន (ទទួលខុសត្រូវគ្មានកម្រិត)

-សមាជិកមានកម្រិត គ្មានសិទ្ធិចូលរួមក្នុងការផ្តល់យោបល់ និង ទទួលព័ត៌មានពីក្រុមហ៊ុន (ទទួលខុសត្រូវមានកម្រិត ត្រឹមដើមទុនដែលបានដាក់។

-មិនអាចចូលហ៊ុន ជាចំណេះបានទេ

-សមាជិកអាចប្រើជំនាញធ្វើការឱ្យក្រុមហ៊ុន និង អាចទទួលបានប្រាក់បៀវត្តន៍

-មិនអាចបោះលក់ Stock បានទេ។

## ២.ទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅប្រទេសកម្ពុជា

-គឺជាក្រុមហ៊ុនដែលបង្កើតឡើងដោយការចុះកិច្ចសន្យា រវាងបុគ្គលពីរនាក់ ឬច្រើននាក់ ធ្វើឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ

-ដោយដាក់រួមគ្នានូវ ទ្រព្យសម្បត្តិ ចំណេះដឹង សាច់ប្រាក់ ឬជំនាញ និង សកម្មភាព ដើម្បីអាជីវកម្មមួយក្នុងគោលបំណង ស្វែងរកប្រាក់ចំណេញ

-ពេលចុះបញ្ជីក្រុមហ៊ុននេះទទួលបាន នីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីសហកម្មសិទ្ធិករម្នាក់ៗ

-សមាជិកទាំងអស់ជាសហកម្មសិទ្ធិករទូទៅ

-សហកម្មសិទ្ធិករទូទៅទាំងអស់ មានសិទ្ធិសម្រេច និង ដឹកនាំអាជីវកម្មស្មើគ្នា

-ការទទួលខុសត្រូវរួមគ្នា ឬដាច់ដោយឡែកពីគ្នា ចំពោះកាតព្វកិច្ចទាំងឡាយរបស់ក្រុមហ៊ុន

-កម្មសិទ្ធិករម្នាក់ៗ ទទួលបានភាគលាភ និង បំណុល ស្មើគ្នា លើកលែងតែ មានចែងដោយឡែក នៅក្នុងកិច្ចព្រមព្រៀង
-សហកម្មសិទ្ធិករម្នាក់ៗ មិនទទួលបានប្រាក់បៀវត្សន៍ពីក្រុមហ៊ុនទេ។

## ៣.ទម្រង់ក្រុមហ៊ុនមូលធនប្រទេសអង់គ្លេស និង ចិន

### I. ក្រុមហ៊ុនមូលធនប្រទេសអង់គ្លេសបែងចែកជាពីរ៖

### 1. ក្រុមហ៊ុនឯកជន

-តម្រូវឱ្យមានលក្ខន្តិកៈ និង ចុះបញ្ជី
-តម្រូវឱ្យមានសមាជិកយ៉ាងតិចម្នាក់
-មិនអនុញ្ញាតឱ្យលក់ភាគហ៊ុនជាសាធារណៈ
-ក្រុមហ៊ុននេះចែកចេញជាពីរគឺ៖

- ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតត្រឹមភាគហ៊ុនរបស់ខ្លួន
    - សមាជិកភាគហ៊ុនទទួលខុសត្រូវចូលរួមបង់នូវចំនួនទឹកប្រាក់ដែលមិនទាន់បង់តាមភាគហ៊ុននិមួយៗ
    - ចំនួនហ៊ុនកាន់កាប់ដោយក្រុមមនុស្សមួយក្រុមតូច
    - ភាគហ៊ុនមិនអាចត្រូវទិញបានដោយសាធារណជនទេ
    - ក្រុមហ៊ុនមិនអាចចុះបញ្ជីលើទីផ្សារហ៊ុន
    - សមាជិកមានកាតព្វកិចលក់ភាគហ៊ុន ទៅឱ្យសមាជិកគ្នាឯងសិន មុនលក់ភាគហ៊ុនឱ្យតតិយជន។
- ក្រុមហ៊ុនទទួលខុសត្រូវ ចូលរួមចំណែកបង់ប្រាក់ដែលតម្រូវសំរាប់ទូទាត់បំណុល

- សមាជិកទទួលខុសត្រូវចំពោះការបង់នូវទ្រព្យចូលក្រុមហ៊ុននូវចំនួនទឹកប្រាក់ដែលតម្រូវសំរាប់ការទូទាត់បំណុលក្រុមហ៊ុន និងសោហ៊ុយចំណាយសំរាប់ជម្រះបញ្ជីរហូតដល់ចំនួនទឹកប្រាក់អតិបរមាដែលមានចែងក្នុងលក្ខន្តិកៈ។

## 2. ក្រុមហ៊ុនសាធារណៈ

-ជាក្រុមហ៊ុនមួយដែលអាចធ្វើអាជីវកម្មលើទីផ្សារភាគហ៊ុនបាន
-ទទួលខុសត្រូវត្រឹមភាគហ៊ុនដែលសមាជិកម្នាក់កាន់
-ក្រុមហ៊ុននេះត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- តែងតាំងអភិបាលយ៉ាងតិច ២នាក់
- មានលេខាធិការក្រុមហ៊ុនម្នាក់
- មានសមាជិកយ៉ាងតិច ២នាក់
- ត្រូវបញ្ជាក់នៅក្នុងលក្ខន្តិកៈថាជា ក្រុមហ៊ុនមហាជន ដោយសរសេរថា Public Limited Company(PLC)
- មានដើមទុនអនុញ្ញាតឱ្យបោះភាគហ៊ុនបាន គឺយ៉ាងតិច ៥០,០០០ផោន
- នៅពេលចាប់ផ្តើមធ្វើពាណិជ្ជកម្មត្រូវមានដើមទុនដែលត្រូវបង់ដោយសមាជិក ១២,៥០០ផោន ក្រុមហ៊ុននេះអាចចុះបញ្ជីក្នុងទីផ្សារភាគហ៊ុនក៏បាន មិនចុះក៏បាន។

# I. ក្រុមហ៊ុនមូលធនប្រទេសចិនបែងចែកជាពីរធំៗ៖

## 1. ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត

-ត្រូវឱ្យមានភាគទុរិកយ៉ាងតិច ២នាក់ ប៉ុន្តែមិនលើសពី ៥០នាក់
-ត្រូវមានដើមទុនអប្បបរមាចន្លោះពី ១០០,០០០ ទៅ ៥០០,០០០ RMB
-ភាគទុរិកទទួលខុសត្រូវចំពោះក្រុមហ៊ុនត្រឹមកម្រិតដើមទុនដែលបានដាក់
-ភាគទុរិកមានសិទ្ធិទទួលបានប្រាក់ចំណេញពីក្រុមហ៊ុន ចូលរួមក្នុងសេចក្តីសម្រេចសំខាន់ៗ

ជ្រើសរើសអ្នកគ្រប់គ្រង និង សិទ្ធិផ្សេងៗទៀត
-ក្នុងការធ្វើសកម្មភាពជំនួញក្រុមហ៊ុនត្រូវគោរពច្បាប់បញ្ញត្តិរដ្ឋបាល សីលធម៌សង្គម សីលធម៌អាជីវកម្ម ធ្វើសកម្មភាពដោយស្មោះត្រង់ និងទទួលយកនូវការត្រួតនិពិត្យពីរដ្ឋាភិបាល ផលប្រយោជន៍សាធារណៈ និង ទទួលខុសត្រូវសង្គម
-ត្រូវចុះបញ្ជីបញ្ជាក់ពីទម្រង់ LLC ឱ្យបានច្បាស់
-តូវបង្កើតលក្ខន្តិកៈ ចងកាតព្វកិច្ច គ្រប់គ្រងភាគទុរិក អ្នកគ្រប់គ្រង អភិបាល
-វិសាលភាពរបស់ក្រុមហ៊ុនត្រូវកំណត់ក្នុងលក្ខន្តិកៈ
-អ្នកតំណាងស្របច្បាប់របស់ក្រុមហ៊ុនគឺ អភិបាល ឬ អ្នកគ្រប់គ្រង
-ក្រុមហ៊ុនអាចបង្កើតសាខា តែត្រូវចុះបញ្ជី
-ក្រុមហ៊ុនអាចបង្កើតបុត្រសម្ព័ន្ធឯករាជ្យបាន។

- **រចនាសម្ព័ន្ធ**
  - មហាសន្និបាតសមាជិកភាគហ៊ុន
  - ក្រុមប្រឹក្សាភិបាល
  - អ្នកចាត់ចែង
  - ក្រុមប្រឹក្សាត្រួតពិនិត្យ